ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ស្ដីពីការជំរុញ និងការការពារវិនិយោគ

នស / រកម / ០៧៩៩ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតាំង-តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រម
# លើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា
# និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ
# ស្តីពីការជំរុញ និងការការពារវិនិយោគ

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល
## នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋ
## កូរ៉េ ស្ដីពីការជំរុញ និងការការពារវិនិយោគ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ស្ដីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅភ្នំពេញ នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តកាលនីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋ ស្ដីទី

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: ១៥៩ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ១៩៩៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជីន កេន

# កិច្ចព្រមព្រៀង

## រវាង

## រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## និង

## រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

## ស្តីពី

## ការជំរុញ និងការការពារវិនិយោគ

# កិច្ចព្រមព្រៀងរវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

# ស្តីពី

# ការជំរុញ និងការការពារវិនិយោគ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ (ចាប់ពីពេលនេះតទៅ ត្រូវបានចាត់ទុកជា «ភាគីកិច្ចសន្យា»)

ដោយមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច រវាងប្រទេសទាំងពីរ

ដោយមានគោលបំណងបង្កើតឡើងនូវលក្ខណៈអនុគ្រោះ សំរាប់ដំណើរការវិនិយោគដែលធ្វើឡើង ដោយវិនិយោគិនទាំងឡាយនៃភាគីកិច្ចសន្យាមួយ នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ដោយឈរលើមូលដ្ឋានស្មើភាពនិងមានផលប្រយោជន៍ទៅវិញទៅមក ។

ដោយទទួលស្គាល់ថាការជំរុញនិងការការពារវិនិយោគលើមូលដ្ឋាននៃកិច្ចព្រមព្រៀងនេះ និង ... ការជំរុញផ្តួចផ្តើមគំនិតអាជីវកម្មក្នុងវិស័យនេះ ។

ភាគីកិច្ចសន្យាទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ ÷

## មាត្រា ១

## និយមន័យ

ក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ÷

(១) ពាក្យ « វិនិយោគ » មានន័យថាទ្រព្យសម្បត្តិគ្រប់ប្រភេទ ដែលបានដាក់អោយដំណើរការវិនិយោគដោយវិនិយោគិននៃភាគីកិច្ចសន្យាមួយ នៅក្នុងទឹកដីរបស់ភាគីកិច្ចសន្យាមួយទៀត

ពិសេស រួមមានទ្រព្យសម្បត្តិដូចខាងក្រោមនេះ (ប៉ុន្តែមិនកំណត់ត្រឹមខ្លឹមសារខាងក្រោមឡើយ) ៖

ក. ចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងសិទ្ធិកាន់កាប់និងកម្មសិទ្ធិដទៃទៀត ដូចជា ការបញ្ចាំអចលនទ្រព្យ ការទារប្រាក់ពីកូនបំណុល និងការសន្យាផ្សេងៗ ។

ខ. ភាគហ៊ុន និងលិខិតបំណុល និងការចូលរួមចំណែកនៅក្នុងក្រុមហ៊ុន ឬសហគ្រាសអាជីវកម្មណាមួយតាមប្រភេទផ្សេងៗ ។

គ. សិទ្ធិទាមទារប្រាក់ ឬការងារដទៃទៀតដែលមានតម្លៃជាទឹកប្រាក់ តាមលក្ខខណ្ឌនៃកិច្ចសន្យា ។

ឃ. សិទ្ធិលើកម្មសិទ្ធិបញ្ញា ដោយគិតបញ្ចូលទាំងការរក្សាសិទ្ធិចំលង ប្រកាសនីយប័ត្រ តក្កកម្ម ពាណិជ្ជសញ្ញា នាមពាណិជ្ជ គំរូឧស្សាហកម្ម បែបបទបច្ចេកទេស ការសំងាត់ពាណិជ្ជកម្ម ចំណេះធ្វើ និងកេរ្តិ៍ឈ្មោះជំនួញ ។

ង. សម្បទានអាជីវកម្មដែលផ្តល់ផលតំលៃសេដ្ឋកិច្ច ហើយដែលទទួលស្គាល់ដោយច្បាប់ ឬតាមកិច្ចសន្យា រួមទាំងសម្បទានសំរាប់ការស្រាវជ្រាវ និស្សារណកម្ម ការរុករក ឬការធ្វើអាជីវកម្មលើធនធានធម្មជាតិ ។

ច. ទុនវិនិយោគក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាផ្ទាល់ ដែលស្ថិតនៅក្នុងការចាត់ចែងរបស់អ្នកដែលនៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀង ដោយអនុលោមទៅតាមច្បាប់និងបទបញ្ញត្តិនៃភាគីនោះ ។

ការប្រែប្រួលបែបផែននានាលើទ្រព្យសម្បត្តិដែលបានវិនិយោគ នឹងមិនត្រូវប៉ះពាល់ដល់ចំណាត់ថ្នាក់ជាវិនិយោគឡើយ ។

(២) ពាក្យ «ប្រាក់ចំណូល» មានន័យថាចំនួនទឹកប្រាក់ដែលបានផលពីការធ្វើវិនិយោគ ជាពិសេស មានរួម (តែមិនកំណត់ត្រឹមខ្លឹមសារខាងក្រោមឡើយ) ប្រាក់ចំណេញ ការប្រាក់កំណើនដើមទុន ប្រាក់ចំណេញលើភាគហ៊ុន ចំណូលពីការលក់ស្នាដៃនិងថ្លៃឈ្នួលផ្សេងៗ ។

(៣) «វិនិយោគិន» មានន័យថារូបវន្តបុគ្គល ឬ និតិបុគ្គលនៃភាគីកិច្ចសន្យាមួយ ដែលធ្វើវិនិយោគនៅលើទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀត ។

(ក) ពាក្យ « រូបវន្តបុគ្គល » មានន័យថា រូបបុគ្គលដែលមានសញ្ជាតិរបស់ភាគីកិច្ចសន្យា ស្របទៅតាមច្បាប់របស់ប្រទេសខ្លួន និង

(ខ) ពាក្យ «និតិបុគ្គល» មានន័យថា អង្គភាព ដូចជាក្រុមហ៊ុន ស្ថាប័ន សាធារណៈ អាជ្ញាធរ ផែនការ ក្រុមហ៊ុន គ្រឹះស្ថាន អង្គការ សាជីវកម្ម ឬ សមាគមដែលចុះឈ្មោះ ឬដែលបានបង្កើតឡើងស្របតាមច្បាប់និងបទបញ្ញត្តិនៃភាគីកិច្ចសន្យានោះ ។

(៤) «ទឹកដី» មានន័យថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬ ទឹកដីនៃសាធារណរដ្ឋកូរ៉េ ព្រមទាំងតំបន់ដែនសមុទ្រ ដែលក្នុងនោះ រាប់បញ្ចូលទាំងបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រដែលជាប់នឹងព្រំដែនខាងក្រៅនៃដែនសមុទ្រ ហើយដែលប្រទេសនោះមានអធិបតេយ្យភាព ឬគ្រប់គ្រងស្របតាមច្បាប់អន្តរជាតិ ក្នុងគោលបំណងរុករក និងធ្វើអាជីវកម្មលើធនធានធម្មជាតិក្នុងតំបន់នោះ ។

(៥) «រូបិយវត្ថុដែលអាចផ្លាស់ប្តូរបានដោយសេរី» មានន័យថា រូបិយវត្ថុដែលត្រូវបានប្រើប្រាស់ជាទូទៅ សំរាប់ទូទាត់ក្នុងកិច្ចការពាណិជ្ជកម្មអន្តរជាតិ ហើយដែលត្រូវផ្លាស់ប្តូរជាទូលំទូលាយ នៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ ។

មាត្រា ២

ការជំរុញ និងការការពារវិនិយោគ

(១) ភាគីកិច្ចសន្យានីមួយៗ ត្រូវលើកទឹកចិត្តនិងបង្កើតលក្ខណៈអំណោយផលសំរាប់វិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគនៅក្នុងទឹកដីរបស់ខ្លួន និងត្រូវអនុញ្ញាតអោយធ្វើសកម្មភាពវិនិយោគ ស្របតាមច្បាប់និងបទបញ្ញត្តិរបស់ប្រទេសខ្លួន ។

(២) ការវិនិយោគរបស់វិនិយោគិននៃភាគីកិច្ចសន្យានីមួយៗ ត្រូវទទួលនូវប្រព្រឹត្តកិច្ចយុត្តិធម៌ និងស្មើភាព ហើយត្រូវទទួលនូវការការពារនិងសន្តិសុខពេញលេញ នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀត ។

(៣) ភាគីកិច្ចសន្យានីមួយៗ មិនត្រូវរារាំង ដោយវិធានការមិនសមហេតុផលឬលំអៀង ចំពោះកិច្ចដំណើរការ ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផលឬការរំសាយវិនិយោគរបស់វិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួនឡើយ ។

(៤) ភាគីកិច្ចសន្យានីមួយៗ ត្រូវគោរពកាតព្វកិច្ចទាំងឡាយ ដែលស្របនឹងកិច្ចព្រមព្រៀងនេះ ចំពោះរាល់សកម្មភាពវិនិយោគរបស់ភាគីកិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ៣
## ប្រព្រឹត្តកិច្ចនៃវិនិយោគ

(១) ភាគីកិច្ចសន្យានីមួយៗត្រូវយល់ព្រមផ្តល់ប្រព្រឹត្តកិច្ចយុត្តិធម៌និងស្មើភាព ចំពោះវិនិយោគ ឬចំណូលដែលបានមកពីការវិនិយោគរបស់ភាគីកិច្ចសន្យាមួយទៀត ហើយប្រព្រឹត្តកិច្ចនេះមិនត្រូវតិចជាងអ្វីដែលបានផ្តល់ចំពោះវិនិយោគឬចំណូលនៃវិនិយោគរបស់ខ្លួន ឬ ចំពោះវិនិយោគនិងចំណូលរបស់វិនិយោគិននៃប្រទេសទីបី ប្រសិនបើប្រព្រឹត្តកិច្ចក្រោយនេះមានភាពអនុគ្រោះច្រើនជាង ។

(២) ភាគីកិច្ចសន្យានីមួយៗ ត្រូវផ្តល់ចំពោះវិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួន នូវប្រព្រឹត្តកិច្ចយុត្តិធម៌និងស្មើភាព សំរាប់ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផលឬការរំសាយវិនិយោគរបស់គេ ហើយប្រព្រឹត្តកិច្ចនេះមិនត្រូវតិចជាងអ្វីដែលបានផ្តល់ចំពោះវិនិយោគិនរបស់ខ្លួន ឬចំពោះវិនិយោគិននៃប្រទេសទីបី ប្រសិនបើប្រព្រឹត្តកិច្ចក្រោយនេះមានភាពអនុគ្រោះជាង ។

(៣) បទបញ្ញត្តិនៃកថាខ័ណ្ឌ (១) និង (២) នៃមាត្រានេះ មិនត្រូវបកស្រាយ ដើម្បីចាប់បង្ខំភាគីកិច្ចសន្យាម្ខាងអោយផ្តល់ដល់វិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត នូវប្រព្រឹត្តកិច្ច ភាពអនុគ្រោះ ឬ សិទ្ធិប្រយោជន៍ណាមួយស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ ឬ កិច្ចសំរុះសំរួល ឬ ច្បាប់ក្នុងប្រទេស ដែលពាក់ព័ន្ធទាំងស្រុងឬជាចំបង ទៅនឹងការយកពន្ធឡើយ ។

## មាត្រា ៤

## ការទូទាត់សំណងចំពោះការខាតបង់

(១) វិនិយោគិននៃភាគីកិច្ចសន្យាម្ខាង ដែលទទួលរងការខាតបង់នៅក្នុងដំណើរការវិនិយោគរបស់ខ្លួន ដោយសារសង្គ្រាមឬជំលោះអាវុធផ្សេងៗ ការបះបោរ កុប្បកម្ម គ្រោះអាសន្នរបស់ប្រទេសជាតិ ចលនាប្រឆាំងឬស្ថានភាពប្រហាក់ប្រហែលផ្សេងៗទៀត នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀត នឹងត្រូវផ្តល់ដោយភាគីកិច្ចសន្យានោះ នូវប្រព្រឹត្តកិច្ចអនុគ្រោះ ស្តីពីបដិទាន សំណង ប្រាក់បំពេញខាត ឬ វិធីដោះស្រាយផ្សេងៗទៀត ដែលមិនត្រូវតិចជាងអ្វីដែលត្រូវផ្តល់ចំពោះវិនិយោគិនរបស់ខ្លួន ឬ ចំពោះវិនិយោគិននៃប្រទេសទីបី ប្រសិនបើប្រព្រឹត្តកិច្ចនោះមានលក្ខណៈអនុគ្រោះច្រើនជាង ។ សំណងទូទាត់នេះ នឹងត្រូវផ្ទេរបាន ដោយសេរី និងដោយគ្មានពន្យាពេលឡើយ ។

(២) ដោយមិនប៉ះពាល់ដល់លក្ខខណ្ឌនៅក្នុងកថាខណ្ឌ (១) នៃមាត្រានេះ វិនិយោគិននៃភាគីកិច្ចសន្យាណាមួយ ដែលស្ថិតក្នុងស្ថានភាពដូចមានចែងនៅក្នុងកថាខណ្ឌនេះត្រូវទទួលរងការខាតបង់នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀត÷

(ក) ការដកហូតទ្រព្យសម្បត្តិដោយកងកម្លាំង ឬដោយអាជ្ញាធររបស់ខ្លួន

(ខ) ការបំផ្លាញទ្រព្យសម្បត្តិដោយកងកម្លាំង ឬ ដោយអាជ្ញាធររបស់ខ្លួន ដែលមិនមែនបណ្តាលមកពីសកម្មភាពប្រយុទ្ធ ឬដែលស្ថានការមិនតម្រូវចាំបាច់

ត្រូវទទួលសងវិញ ឬ ទូទាត់សំណងយ៉ាងសមស្រប ហើយមិនត្រូវតិចជាងអ្វីដែលបានផ្តល់ចំពោះវិនិយោគិននៃប្រទេសទីបី នៅក្នុងកាលៈទេសៈដូចគ្នាឡើយ ។ ការទូទាត់សំណងនេះ នឹងត្រូវផ្ទេរដោយសេរី និងដោយគ្មានពន្យាពេលឡើយ ។

## មាត្រា ៥

## ការដកហូត

(១) ការវិនិយោគរបស់វិនិយោគិននៃភាគីកិច្ចសន្យាម្ខាង មិនត្រូវធ្វើជាតូបនីយកម្ម ឬដកហូត ឬការវិធានការផ្សេងៗទៀតដែលមានផលស្មើនឹងការធ្វើជាតូបនីយកម្ម ឬការដកហូត

(តទៅនេះហៅថា ការដកហូត) ទៅក្នុងទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀតឡើយ លើកលែងតែក្នុងគោលបំណងប្រយោជន៍សាធារណៈ ហើយត្រូវអនុវត្តឡើង ដោយទូទាត់សំណងជាក់ស្តែងភ្លាមៗនិងត្រឹមត្រូវ ។ ការដកហូតនេះត្រូវអនុវត្តដោយគ្មានរើសអើងតាមនីតិវិធីស្របច្បាប់ ។

(២) ការទូទាត់សំណងនេះត្រូវគិតតាមតំលៃសមស្របរបស់ទីផ្សារ មុនពេលដកហូត ឬ មុនពេលការសំរេចដកហូតនេះត្រូវបានប្រកាសជាសាធារណៈ ដោយត្រូវរាប់បញ្ចូលទាំងការប្រាក់តាមអត្រាពាណិជ្ជកម្ម នាពេលនោះ ដោយគិតចាប់ពីថ្ងៃដកហូតរហូតដល់ថ្ងៃទូទាត់ ។ សំណងនេះត្រូវទូទាត់ដោយគ្មានការពន្យាពេល និងអនុវត្តដោយដោយ ប្រសិទ្ធិភាព ព្រមទាំងអាចផ្ទេរបានដោយសេរី ។ ប្រព្រឹត្តកិច្ចនៃការដកហូតនិងការទូទាត់សំណងមិនត្រូវមានភាពអនុគ្រោះតិចជាងអ្វីដែលត្រូវផ្តល់ចំពោះវិនិយោគិនរបស់ខ្លួន ឬ ចំពោះវិនិយោគិននៃប្រទេសទីបីឡើយ ។

(៣) វិនិយោគិននៃភាគីកិច្ចសន្យាម្ខាង ដែលត្រូវរងគ្រោះដោយសារការដកហូត ត្រូវមានសិទ្ធិស្នើទៅតុលាការឬអាជ្ញាធរឯករាជ្យនៃភាគីចុះកិច្ចសន្យាម្ខាងទៀត អោយពិនិត្យឡើងវិញ អំពីករណីរបស់ខ្លួននឹងអំពីការវាយតំលៃវិនិយោគរបស់ខ្លួន ស្របតាមគោលការណ៍ដូចបានចែងនៅក្នុងមាត្រានេះ ។

(៤) បទបញ្ញត្តិនៃមាត្រានេះត្រូវអនុវត្ត ចំពោះករណីដែលភាគីកិច្ចសន្យាម្ខាងដកហូតទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមួយ ដែលបានចុះបញ្ជីស្របតាមច្បាប់និងបទបញ្ញត្តិរបស់ខ្លួន ហើយដែលក្នុងនោះ វិនិយោគិននៃភាគីចុះកិច្ចសន្យាម្ខាងទៀតបានចូលរួមចំណែក ឬ មានភាគហ៊ុន ឬ មានលិខិតបំណុល ។

មាត្រា ៦

ការផ្ទេរ

(១) ភាគីកិច្ចសន្យានីមួយៗ ត្រូវធានាចំពោះវិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត នូវការផ្ទេរដោយសេរី នូវវិនិយោគនិងប្រាក់ចំណូលរបស់ខ្លួន ។ ការផ្ទេរនេះត្រូវគិតបញ្ចូល ជាពិសេស (តែមិនកំរិតត្រឹមខ្លឹមសារទាំងនេះឡើយ) នូវ ÷

(ក) ប្រាក់ចំណេញ កំណើនដើមទុន ប្រាក់ចំណេញតាមភាគហ៊ុន ការប្រាក់ចំណូលពីការលក់ស្នាដៃ ថ្លៃឈ្នួល និងចំណូលផ្សេងៗទៀតដែលបានមកពីការវិនិយោគ ។

(ខ) ចំណូលដែលបានមកពីការលក់ ឬ ការរំលាយទាំងស្រុង ឬមួយផ្នែកនៃវិនិយោគ ។

(គ) មូលនិធិសំរាប់សងឥណទាន ដែលបានខ្ចីសំរាប់ធ្វើវិនិយោគ ។

(ឃ) ចំណូលរបស់ពលរដ្ឋនៃភាគីកិច្ចសន្យាម្ខាងទៀត ដែលអនុញ្ញាត្តិអោយមកបំរើការងារ វិនិយោគ នៅក្នុងទឹកដីរបស់ខ្លួន ។

(ង) មូលនិធិបន្ថែមចាំបាច់សំរាប់ថែរក្សា ឬពង្រីកវិនិយោគដែលមានស្រាប់ ។

(ច) ចំនួនទឹកប្រាក់ដែលចំណាយសំរាប់ការគ្រប់គ្រងកិច្ចការវិនិយោគ នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀត ឬ នៅក្នុងប្រទេសទី៣ ។

(ឆ) ការទូរទាត់សំណងដែលមានចែងក្នុងមាត្រា ៤ និង ៥ ។

(២) រាល់ការផ្ទេរទាំងឡាយក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តតាមរូបិយវត្ថុដែលអាចប្តូរបានដោយសេរី និងដោយគ្មានការរឹតត្បិតនិងគ្មានបង្អង់ពេលដោយមិនសមហេតុផល ទៅតាមអត្រាប្តូរប្រាក់ដែលមានប្រសិទ្ធិភាពសំរាប់ប្រតិបត្តិការប្រចាំថ្ងៃ ឬ ត្រូវកំណត់តាមអត្រាប្តូរប្រាក់ផ្លូវការដែលមានប្រសិទ្ធិភាពនាថ្ងៃផ្ទេរនោះ ប្រសិនបើលក្ខខ័ណ្ឌមានភាពអនុគ្រោះជាង ។

## មាត្រា ៧
## ការផ្ទេរសិទ្ធិបន្ត

ប្រសិនបើភាគីកិច្ចសន្យាណាមួយ ឬភ្នាក់ងារចាត់តាំងរបស់គេបានបង់ប្រាក់ទៅអោយវិនិយោគិនរបស់ខ្លួន ដើម្បីធានាសងចំពោះការវិនិយោគ ភាគីកិច្ចសន្យាម្ខាងទៀតត្រូវទទួលស្គាល់នូវៈ

(ក) ការផ្ទេរសិទ្ធិ ឬការករទាមទាររបស់វិនិយោគិនចំពោះភាគីកិច្ចសន្យាដើម ឬ ភ្នាក់ងារចាត់តាំងរបស់គេ ដោយអនុលោមតាមច្បាប់ ឬអនុលោមតាមការធ្វើអាជីវកម្មស្របច្បាប់នៅក្នុងប្រទេសនោះ ។

(ខ) ភាគីកិច្ចសន្យាដើម ឬ ភ្នាក់ងារចាត់តាំងរបស់ខ្លួន ដោយសារមានការផ្ទេរសិទ្ធិជំនួសនេះ មានសិទ្ធិអនុវត្តនិងទាមទារតវ៉ាពីវិនិយោគិនទាំងនោះ ។

## មាត្រា ៨

## ដំណោះស្រាយជំលោះវិនិយោគ រវាងភាគីកិច្ចសន្យាមួយ ជាមួយនឹងវិនិយោគិនរបស់ភាគីកិច្ចសន្យាម្ខាងទៀត

(១) រាល់ជំលោះរវាងភាគីកិច្ចសន្យាម្ខាង និងវិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត រួមទាំងការដកហូតឬជាតូបនីយកម្មនៃវិនិយោគ ត្រូវដោះស្រាយតាមស្មារតីយោគយល់គ្នា រវាងបណ្តាភាគីក្នុងជំលោះ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

(២) មធ្យោបាយដោះស្រាយនៅក្នុងប្រទេស ស្របតាមច្បាប់និងបទបញ្ញត្តិនៃភាគីកិច្ចសន្យាមួយ ដែលវិនិយោគបានដំណើរការនៅក្នុងទឹកដីរបស់ភាគីនោះ ត្រូវផ្តល់ទៅវិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត លើមូលដ្ឋាននៃប្រព្រឹត្តកិច្ចអនុគ្រោះមិនតិចជាងអ្វីដែលត្រូវផ្តល់ចំពោះវិនិយោគិនរបស់ខ្លួន ឬ ចំពោះវិនិយោគិននៃប្រទេសទីបី ប្រសិនបើប្រព្រឹត្តកិច្ចនោះមានអនុគ្រោះច្រើនជាង ។

(៣) ប្រសិនបើជំលោះមិនអាចដោះស្រាយក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃដែលវិវាទត្រូវបង្កឡើងដោយភាគីណាមួយ យោងតាមការស្នើរបស់ភាគីម្ខាង ជំលោះនោះត្រូវស្នើជូនមជ្ឈមណ្ឌលអន្តរជាតិដើម្បីដោះស្រាយជំលោះវិនិយោគ ដែលបានបង្កើតឡើងដោយអនុសញ្ញានៅទីក្រុងវ៉ាស៊ីនតោន ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៩៦៥ ស្តីពីដំណោះស្រាយជំលោះវិនិយោគរវាងរដ្ឋនានា និង ជនជាតិនៃរដ្ឋដទៃទៀត ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញានេះ ។ មុនពេលស្នើជូនមជ្ឈមណ្ឌលអន្តរជាតិនេះ ជំលោះត្រូវដោះស្រាយតាមការ ផ្សះផ្សាឬតាមអាជ្ញាកណ្តាលតាមការព្រមព្រៀងគ្នាលើមូលដ្ឋាននៃអនុសញ្ញានេះ ឬ តាមនីតិវិធីបន្ថែមផ្សេងទៀត ។

(៤) សេចក្តីសំរេចរបស់មជ្ឈមណ្ឌលអន្តរជាតិដើម្បីដោះស្រាយជំលោះវិនិយោគនេះ គឺជាសេចក្តីសំរេចជាចុងក្រោយដែលតំរូវអោយបណ្តាភាគីជំលោះអនុវត្ត ។ ភាគីកិច្ចសន្យានីមួយៗត្រូវទទួលស្គាល់និងអនុវត្តតាមសេចក្តីសំរេចនេះ ស្របតាមច្បាប់និងបទបញ្ញត្តិរបស់ខ្លួន ។

## មាត្រា ៩

## ដំណោះស្រាយជំលោះរវាងភាគីកិច្ចសន្យា

(១) ជំលោះរវាងភាគីកិច្ចសន្យាដែលពាក់ព័ន្ធទៅនឹងបំណកស្រាយ ឬ ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយតាមការពិគ្រោះយោបល់ឬតាមរយៈការទូត ប្រសិនបើអាចធ្វើទៅបាន ។

(២) ប្រសិនបើជំលោះមិនអាចដោះស្រាយបាន ក្នុងរយៈពេលប្រាំមួយខែ (៦) ស្របតាមបទបញ្ញត្តិនៃមាត្រានេះ វិវាទនេះត្រូវដាក់ជូនសាលាមជ្ឈត្តវិនិច្ឆ័យពិនិត្យ ។

(៣) សាលាមជ្ឈត្តវិនិច្ឆ័យនេះ ត្រូវបានបង្កើតទៅតាមករណីនីមួយៗ តាមបែបបទដូចតទៅ : ក្នុងរយៈពេលពីរ (២) ខែ ចាប់ពីថ្ងៃទទួលសំណើមក ភាគីកិច្ចសន្យានីមួយៗត្រូវតែងតាំងសមាជិកម្នាក់នៃសាលាមជ្ឈត្តវិនិច្ឆ័យ ។ បន្ទាប់មក សមាជិកទាំងពីរនេះត្រូវជ្រើសរើសជនជាតិនៃរដ្ឋទីពម្នាក់ ហើយដោយមានការយល់ព្រមពីភាគីកិច្ចសន្យាទាំងពីរ នឹងត្រូវបានតែងតាំងជាប្រធានសាលាមជ្ឈត្តវិនិច្ឆ័យ ។ ប្រធានសាលាមជ្ឈត្តវិនិច្ឆ័យត្រូវបានតែងតាំងក្នុងរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃតែងតាំងសមាជិកទាំងពីរនោះរួចមក ។

(៤) នៅក្នុងរយៈពេលដូចដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ប្រសិនបើការតែងតាំងមិនទាន់បានអនុវត្តទេនោះ ភាគីកិច្ចសន្យាណាមួយអាចលើកសំណើទៅប្រធានតុលាការអន្តរជាតិ ដើម្បីធ្វើការតែងតាំងទាំងនេះ ។ ប្រសិនបើប្រធានតុលាការអន្តរជាតិនេះជាជនជាតិនៃភាគីចុះកិច្ចសន្យាណាមួយ ឬក៏មិនអាចបំពេញមុខងារនេះបាន ដោយសារប្រការណាមួយនោះ អនុប្រធានត្រូវបានអញ្ជើញអោយធ្វើការតែងតាំង ។ ប្រសិនបើអនុប្រធានក៏ជាជនជាតិនៃភាគីចុះកិច្ចសន្យាណាមួយ ឬ មិនអាចបំពេញមុខងារនេះបាន សមាជិករបស់តុលាការអន្តរជាតិ ដែលមានលំដាប់ខ្ពស់ជាងគេហើយដែលមិនមែនជាជនជាតិនៃភាគីកិច្ចសន្យាណាមួយត្រូវបានអញ្ជើញអោយធ្វើការតែងតាំងនេះ ។

(៥) សាលាមជ្ឈត្តវិនិច្ឆ័យនឹងធ្វើការសំរេចដោយសំលេងឆ្នោតភាគច្រើន ។ សេចក្តីសំរេចនេះមានប្រសិទ្ធិភាពយ៉ាងពេញទំហឹងទៅលើភាគីកិច្ចសន្យាទាំងពីរ ។

(៦) ភាគីកិច្ចសន្យានីមួយៗត្រូវទទួលបន្ទុកចំណាយសំរាប់អាជ្ញាកណ្តាល និងតំណាងរបស់ខ្លួន នៅក្នុងដំណើរការកាត់ក្តី ។ ភាគីកិច្ចសន្យាទាំងពីរត្រូវទទួលបន្ទុកស្មើគ្នា នូវចំណាយសំរាប់ប្រធាននិងចំណាយផ្សេងៗទៀត ។ ប៉ុន្តែ សាលាមជ្ឈត្តវិនិច្ឆ័យអាចសំរេចអោយភាគីណាមួយបង់ចំណាយខ្ពស់ជាងភាគីកិច្ចសន្យាមួយទៀត ។ សាលាមជ្ឈត្តវិនិច្ឆ័យត្រូវកំណត់វិធានបទដំណើរការរបស់ខ្លួន ។

## មាត្រា ១០

## ការអនុវត្តច្បាប់ផ្សេងៗ

(១) នៅពេលដែលការងារមួយត្រូវបានដោះស្រាយព្រមគ្នា តាមកិច្ចព្រមព្រៀងនេះ និងតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលភាគីកិច្ចសន្យាទាំងពីរជាភាគីនៃកិច្ចព្រមព្រៀងនោះ ឬ តាមគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ គ្មានប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះអាចរារាំងភាគីកិច្ចសន្យាឬវិនិយោគិន មិនអោយប្រើប្រាស់ច្បាប់ដែលមានភាពអនុគ្រោះជាងគេ សំរាប់ករណីរបស់ខ្លួនឡើយ ។

(២) ដោយផ្អែកតាមច្បាប់និងបទបញ្ញត្តិរបស់ខ្លួន ឬ តាមបទបញ្ញត្តិពិសេស ឬ តាមកិច្ចសន្យា ប្រសិនបើប្រព្រឹត្តិកិច្ចរបស់ភាគីកិច្ចសន្យាមួយ ចំពោះវិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត បានផ្តល់ភាពអនុគ្រោះច្រើនជាងកិច្ចព្រមព្រៀងនេះ ប្រព្រឹត្តិកិច្ចដែលផ្តល់ភាពអនុគ្រោះច្រើនជាងនោះ នឹងត្រូវយកមកអនុវត្ត ។

(៣) ភាគីកិច្ចសន្យានីមួយៗត្រូវគោរពកាតព្វកិច្ចផ្សេងៗទៀត ចំពោះកិច្ចការវិនិយោគដែលធ្វើឡើងដោយវិនិយោគិននៃភាគីកិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ១១

## ការអនុវត្តន៍កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះរាល់សកម្មភាពវិនិយោគ ទោះបីជាធ្វើមុន ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ក៏ប៉ុន្តែ មិនត្រូវអនុវត្តចំពោះជំលោះណាដែលទាក់ទងនឹងកិច្ចការវិនិយោគដែលត្រូវបានដោះស្រាយមុនពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមានឡើយ ។

## ការចូលជាធរមាន រយៈពេល និងការបញ្ចប់កិច្ចព្រមព្រៀង

(១) កិច្ចព្រមព្រៀងនេះនឹងត្រូវចូលជាធរមាន នៅក្រោយរយៈពេលសាមសិប (៣០)ថ្ងៃ បន្ទាប់ពីថ្ងៃចុះហត្ថលេខា ។

(២) កិច្ចព្រមព្រៀងនេះត្រូវស្ថិតនៅជាធរមានសំរាប់រយៈពេល ១៥ ឆ្នាំ ហើយត្រូវនៅជាធរមានបន្តទៀតដោយគ្មានកំណត់រយៈពេលវេលា លើកលែងតែភាគីកិច្ចសន្យាណាមួយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីកិច្ចសន្យាម្ខាងទៀត មួយឆ្នាំមុន អំពីគោលបំណងរបស់ខ្លួនក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះ ។

(៣) ចំពោះវិនិយោគដែលបានធ្វើមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ បទបញ្ញត្តិទាំងឡាយនៃមាត្រា ១ ដល់ ១១ នៃកិច្ចព្រមព្រៀងនេះត្រូវស្ថិតនៅជាធរមានសំរាប់រយៈពេលបន្ត ២០ ឆ្នាំទៀត គិតពីថ្ងៃបញ្ចប់នេះ ។

ដើម្បីទុកជាសក្ខីភាព ហត្ថលេខីខាងក្រោមបានទទួលសិទ្ធិយ៉ាងពេញច្បាប់ពីរដ្ឋាភិបាលរបស់ខ្លួនដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ជាភាសាខ្មែរ កូរ៉េ និង អង់គ្លេស អត្ថបទទាំងអស់មានតំលៃស្មើគ្នាតាមផ្លូវច្បាប់ ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាគោល ។

| | |
|---|---|
| តំណាងអោយរាជរដ្ឋាភិបាលនៃ | តំណាងអោយរដ្ឋាភិបាលនៃ |
| ព្រះរាជាណាចក្រកម្ពុជា | សាធារណរដ្ឋកូរ៉េ |
| | Kyung T. Park |